ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍ
សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍

លេខ ០០១ សកត.ទសអស

ថ្ងៃ ចន្ទ ៤កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០២២

រដ្ឋបាលខេត្តព្រះវិហារ
ចូល លេខ: ១១៥៣ [illegible]
ថ្ងៃទី ៨ ខែ ៨ ឆ្នាំ ២០២២
ម៉ោង

# ប្រកាស
## ស្ដីពី
## ការទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

- បានឃើញសេចក្ដីសម្រេចលេខ ៩៩ សសរ. ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍
- យោងលទ្ធផលនៃកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងពង្រឹងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងលើកកម្ពស់សកម្មភាពសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ដើម្បីបង្កើនការទាក់ទាញទេសចរជាតិ និងអន្តរជាតិ។

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅកំណត់អំពីវិធាន និងយន្តការទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសហគមន៍ទាំងឡាយណាដែលមានសក្ដានុពល និងដែលត្រូវបានរៀបចំជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ ._**

បច្ចេកស័ព្ទសំខាន់ដែលប្រើក្នុងប្រកាសនេះមានន័យ ដូចខាងក្រោម ៖

- **សហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍** សំដៅដល់ទីតាំង ឬកន្លែងទាក់ទាញទេសចរណ៍ ឬអេកូទេសចរណ៍ ដែលរៀបចំដោយសហគមន៍មូលដ្ឋានខ្លួនឯងផ្ទាល់ ឬដោយមានកិច្ចសហប្រតិបត្តិការដើម្បីពង្រឹងកិច្ចអភិវឌ្ឍមូលដ្ឋានក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍ និងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង និងទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

**ប្រការ៥ ._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ វាយតម្លៃការផ្ដល់ ការលុបចោល ឬការព្យួរលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។

## ជំពូកទី៣
## វិធាន និងនីតិវិធីក្នុងការទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍



CamScanner

**ប្រការ៦ ._**

សហគមន៍ដែលមានសក្តានុពលទេសចរណ៍ ឬអេកូទេសចរណ៍ និងដែលត្រូវបានរៀបចំជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំទទួលស្គាល់ដោយផ្ទាល់នៅគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួន ដូចខាងក្រោម៖

១.ពាក្យស្នើសុំទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍

២.លិខិតអនុញ្ញាតបង្កើតសហគមន៍ (ចេញដោយក្រសួងមហាផ្ទៃ ឬដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬដោយរដ្ឋបាលរាជធានី ខេត្ត)

៣.ឯកសារស្តីពីលក្ខន្តិកៈសហគមន៍ បទបញ្ជាផ្ទៃក្នុង ឬឯកសារសមមូល

៤.លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ប្រធានសហគមន៍ (កិច្ចសន្យាគោរពច្បាប់រដ្ឋ)

៥.តារាងត្រួតពិនិត្យព័ត៌មាន និងទិន្នន័យអំពីសហគមន៍

៦.ឯកសារនានាពាក់ព័ន្ធនឹងការបង្កើតសហគមន៍

៧.អត្តសញ្ញាណប័ណ្ណ

៨.រូបថត ៤x៦ របស់ប្រធានសហគមន៍។

**ប្រការ៧ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពដោយផ្ទាល់ពីក្រសួងទេសចរណ៍ ឬតាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត ដោយត្រូវបំពេញសំណុំបែបបទរួមទាំងឯកសារសំអាង និងព័ត៌មានមួយចំនួន ដូចខាងក្រោម៖

១.ពាក្យស្នើសុំបន្តសុពលភាពជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍

២.លិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ (ថតចម្លង)

៣.លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ប្រធានសហគមន៍ (កិច្ចសន្យាគោរពច្បាប់រដ្ឋ)

៤.តារាងត្រួតពិនិត្យព័ត៌មាន និងទិន្នន័យអំពីសហគមន៍

៥.ឯកសារនានាពាក់ព័ន្ធនឹងការបង្កើតសហគមន៍

៦.អត្តសញ្ញាណប័ណ្ណ

៧.រូបថត ៤x៦ របស់ប្រធានសហគមន៍។

**ប្រការ៨ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវធ្វើការជូនដំណឹងមកគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ រាល់ពេលមានការផ្លាស់ប្តូររចនាសម្ព័ន្ធដឹកនាំសហគមន៍ និងការវិវត្តនានាដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចប្រតិបត្តិការរបស់សហគមន៍។

**ប្រការ៩ ._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ នឹងជូនដំណឹងទៅប្រធានសហគមន៍អំពីសេចក្តីសម្រេចឯកភាពផ្តល់ជូនលិខិតទទួលស្គាល់ ឬមិនឯកភាពផ្តល់ឲ្យ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីសហគមន៍បានបំពេញបែបបទត្រឹមត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងប្រកាសនេះ។



CamScanner

**ប្រការ១០ ._**

លិខិតទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ មានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតទទួលស្គាល់ជាផ្លូវការ។

**ប្រការ១១ ._**

ប្រធានសហគមន៍ ត្រូវដាក់ពាក្យសុំបន្តសុពលភាពលិខិតទទួលស្គាល់ ឱ្យបាន ៣០ (សាមសិប) ថ្ងៃ យ៉ាងតិច មុនថ្ងៃផុតកំណត់នៃសុពលភាពលិខិតទទួលស្គាល់ចាស់។

ក្នុងករណីដែលសហគមន៍នៅបន្តប្រើប្រាស់លិខិតទទួលស្គាល់ដែលអស់សុពលភាព នឹងត្រូវចាត់ទុកថាជាការធ្វើសកម្មភាពដោយគ្មានលិខិតទទួលស្គាល់។

## ជំពូកទី៤
## លក្ខខណ្ឌនៃការប្រើប្រាស់លិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

**ប្រការ១២ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក. ត្រូវប្រើប្រាស់លិខិតទទួលស្គាល់ឲ្យបានត្រឹមត្រូវ ស្របតាមកម្មវត្ថុនៃដំណើរការរបស់ខ្លួន និងត្រូវគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងអនុវត្តតាមការណែនាំនានារបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ

ខ. ត្រូវដាក់តាំងលិខិតទទួលស្គាល់នៅកន្លែងទទួលភ្ញៀវដែលងាយមើលឃើញច្បាស់

គ. ក្នុងករណីមានការខូចខាត ឬបាត់បង់លិខិតទទួលស្គាល់ ប្រធានសហគមន៍ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់ និងមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំលិខិតទទួលស្គាល់ថ្មីពីគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលខូចខាត ឬបាត់បង់។

## ជំពូកទី៥
## កម្រៃក្នុងការស្នើសុំលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

**ប្រការ១៣ ._**

ការស្នើសុំទទួលស្គាល់ជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ មិនតម្រូវឱ្យមានការបង់កម្រៃឡើយ។

## ជំពូកទី៦
## ភារកិច្ចរបស់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

**ប្រការ១៤ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវអនុវត្តតាមភារកិច្ចដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់ស្តីពីទេសចរណ៍ អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដាសហគមន៍ទេសចរណ៍កម្ពុជា និងបទប្បញ្ញត្តិគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។



CamScanner

**ប្រការ១៥ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវរៀបចំផែនការ និងសកម្មភាពបណ្តុះបណ្តាលដល់សមាជិកអំពីជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច និងជំនាញចាំបាច់នានា ស្របតាមការណែនាំរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។

**ប្រការ១៦ ._**

សហគមន៍ដែលត្រូវបានទទួលស្គាល់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ត្រូវផ្តល់របាយការណ៍ និងស្ថិតិអំពីសហគមន៍របស់ខ្លួនជូនគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ តាមការស្នើសុំរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ១៧ ._**

ជនណាដែលក្លែងលិខិតទទួលស្គាល់សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ១៨ ._**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩ ._**

អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ប្រធានគណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ. គណៈកម្មាធិការជាតិ (គ.ជ.អ.អ.)**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត

៤x៦

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍ

សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

## ពាក្យស្នើសុំ

## ទទួលស្គាល់ជាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ............................................................. អក្សរឡាតាំង ..............................................................................

ថ្ងៃខែឆ្នាំកំណើត.............................................ភេទ...........អត្តសញ្ញាណប័ណ្ណលេខ .........................................................

អាសយដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ ............................ ផ្លូវ/ភូមិ ........................... សង្កាត់/ឃុំ........................................

ខណ្ឌ/ស្រុក ........................................................... រាជធានី/ខេត្ត.......................................................................

មុខរបរ..................................................តំណាងឱ្យសហគមន៍.......................................................................

### សូមគោរពជូន

### ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍ

### សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតទទួលស្គាល់សហគមន៍............................................................................................ ជាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំ ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធាន (គ.ជ.អ.អ.) មេត្តាពិនិត្យ និងអនុញ្ញាតទទួលស្គាល់សហគមន៍.......................................................................................

ជាអក្សរឡាតាំង.........................................................................................................................................

ដែលមានអាសយដ្ឋាន ...............................................................................................................................

លេខទំនាក់ទំនង ..............................................ទូរស័ព្ទ..................................អ៊ីម៉ែល..................................

ជាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធាន (គ.ជ.អ.អ.) មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

**សូមជូនភ្ជាប់ជាមួយ៖**

១- លិខិតអនុញ្ញាតបង្កើតសហគមន៍ (ចេញដោយក្រសួងមហាផ្ទៃ ឬដោយក្រសួងមានសមត្ថកិច្ច ឬដោយរដ្ឋបាលរាជធានី ខេត្ត) ...............................................................................០១ច្បាប់

២- លក្ខន្តិកៈសហគមន៍ បទបញ្ជាផ្ទៃក្នុង ឬឯកសារសមមូល ..............................................០១ច្បាប់

៣- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន.......................................................................០១ច្បាប់

៤- លិខិតយល់ព្រមជាលាយល័ក្ខអក្សររបស់ប្រធានសហគមន៍ (កិច្ចសន្យាគោរពច្បាប់រដ្ឋ)...........០១ច្បាប់

៥- តារាងត្រួតពិនិត្យ ព័ត៌មាន និងទិន្នន័យអំពីសហគមន៍.......................................................០១ច្បាប់

៦- រូបថត ៤x៦ របស់ប្រធានសហគមន៍.....................................................................០៤សន្លឹក

CamScanner

សូម ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធាន (គ.ជ.អ.អ.) មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ.......................... ថ្ងៃទី............. ខែ............... ឆ្នាំ.............

ហត្ថលេខា ឬស្នាមមេដៃប្រធានសហគមន៍ និងប្រថាប់ត្រា

បានឃើញ និងឯកភាព

សូមគោរពជូន ឯកឧត្តមរដ្ឋមន្ត្រី និងជាប្រធាន (គ.ជ.អ.អ.)

មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ៗ

ថ្ងៃទី................. ខែ ........................... ឆ្នាំ............

ប្រធានមន្ទីរ..............................

ឈ្មោះ.............................

CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍ
សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

# កិច្ចសន្យាគោរពច្បាប់រដ្ឋ

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ.......................................................... អក្សរឡាតាំង ..........................................................

ថ្ងៃខែឆ្នាំកំណើត.................................... ភេទ............. អត្តសញ្ញាណប័ណ្ណលេខ ..........................................................

អាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ .......................... ផ្លូវ/ភូមិ ........................... សង្កាត់/ឃុំ..................................

ខណ្ឌ/ស្រុក ....................................................... រាជធានី/ខេត្ត...........................................................................

មុខរបរ .............................................................. តំណាងឱ្យសហគមន៍..............................................................

សូមសន្យាចំពោះ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍** (គ.ជ.អ.អ.) ថា ក្រោយពីបានទទួលលិខិតទទួលស្គាល់ជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ខ្ញុំបាទ/នាងខ្ញុំ នឹងធ្វើការអនុវត្តតាមការណែនាំរបស់ក្រសួងទេសចរណ៍ និង (គ.ជ.អ.អ.) ដូចខាងក្រោមៈ

១. មកដាក់ពាក្យស្នើសុំ ឬបន្តលិខិតទទួលស្គាល់ពី (គ.ជ.អ.អ.) ក្នុងរយៈពេល ៣០ថ្ងៃមុន (ចាប់ផ្តើមធ្វើប្រតិបត្តិការ ឬអស់សុពលភាព ឬចាប់ពីថ្ងៃចុះកិច្ចសន្យានេះតទៅ)

២. ធានារក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរចូលកម្សាន្ត

៣. ដាក់តាំងលិខិតទទួលស្គាល់នៅកន្លែង ដែលងាយមើលឃើញច្បាស់ក្នុងបរិវេណសហគមន៍

៤. ផ្តល់ស្ថិតិ និងព័ត៌មានពិតពាក់ព័ន្ធនឹងសហគមន៍ឱ្យបានទាន់ពេលវេលាជូនក្រសួងទេសចរណ៍ និង (គ.ជ.អ.អ.)

៥. សហការ និងរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនូវបាតុភាពអសកម្ម ដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ

៦. អនុវត្តតាមបទប្បញ្ញត្តិ និងការណែនាំនានារបស់ក្រសួងទេសចរណ៍ និង (គ.ជ.អ.អ.)។

ក្នុងករណីដែល ខ្ញុំបាទ/នាងខ្ញុំ ខកខានមិនបានអនុវត្ត ឬអនុវត្តមិនបានពេញលេញតាមចំណុចខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន។

ធ្វើនៅ...................... ថ្ងៃទី..................... ខែ................ ឆ្នាំ.............

**ហត្ថលេខា ឬស្នាមមេដៃប្រធានសហគមន៍ និងប្រថាប់ត្រា**

CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍ**
**សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍**

## តារាងត្រួតពិនិត្យព័ត៌មាន និងទិន្នន័យអំពីសហគមន៍

### I. ទីតាំង និងវិសាលភាព

ឈ្មោះសហគមន៍ (ភាសាខ្មែរ) ..........................................................................................

ភាសាឡាតាំង ..........................................................................................

លេខទូរស័ព្ទទំនាក់ទំនង ..........................................................................................

អាសយដ្ឋានបច្ចុប្បន្ន ..........................................................................................

..........................................................................................

ឈ្មោះប្រធានសហគមន៍ ............................ ភេទ.......... អត្តសញ្ញាណប័ណ្ណលេខ ..............................

អាសយដ្ឋាន .................................................................................... ..............................

.......................................................................... លេខទូរស័ព្ទ ..........................................................

កាលបរិច្ឆេទបង្កើតសហគមន៍ ..........................................................................................

ថ្នាក់សម្រេចបង្កើតសហគមន៍ ..........................................................................................

វិសាលភាព/ផ្ទៃដីគ្រប់គ្រងដោយសហគមន៍ ..........................................................................................

ប្រភេទសហគមន៍៖ ☐ ទេសចរណ៍ ☐ អេកូទេសចរណ៍ ☐ ផ្សេងៗ..............................

### II. ផលិតផល និងសក្តានុពលទេសចរណ៍ និងអេកូទេសចរណ៍ក្នុងសហគមន៍

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

## III. សេវាកម្ម និងតម្លៃសេវាកម្មក្នុងសហគមន៍

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

## IV. ចំនួនបុគ្គលិក ឬសមាជិកសហគមន៍

ចំនួនសរុប................នាក់ ប្រុស................នាក់ ស្រី................នាក់ ផ្សេង..........................................................

## V. ទិសដៅរបស់សហគមន៍

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

ថ្ងៃទី.................. ខែ................ ឆ្នាំ................

មន្ត្រីស្រង់ព័ត៌មាន និងទិន្នន័យ

អ្នករាយការណ៍

ប្រធានសហគមន៍ ឬតំណាង

CS CamScanner